# ខេត្តកំពង់ស្ពឺ

## សក្តានុពលវិនិយោគ

សីហា ឆ្នាំ ២០០៨




# ខេត្តកំពង់ស្ពឺ

## ស្ថាបនាអាជីវកម្មរបស់អ្នកក្នុងដំណើររីកលូតលាស់នៃប្រទេសកម្ពុជា









USAID
ជំនួយពីពលរដ្ឋអាមេរិក

**បញ្ជាក់:**
ទស្សនៈរបស់អ្នកនិពន្ធដែលបង្ហាញនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ មិនបានឆ្លុះបញ្ចាំងអំពី ទស្សនៈរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ ឬ រដ្ឋាភិបាលអាមេរិកនោះទេ។



# របាយការណ៍វិនិយោគនៅខេត្តកំពង់ស្ពឺ


**មតិស្វាគមន៍ពីឯកឧត្តមអភិបាលខេត្ត** ២

**ចំណុចខ្លាំងរបស់ប្រទេស** ៣

បរិយាកាសអាជីវកម្មបើកចំហ
កម្លាំងពលកម្មដែលមានតំលៃទាប
ទីតាំងយុទ្ធសាស្ត្រក្នុងតំបន់

**ហេតុអ្វីត្រូវជ្រើសរើសយកខេត្តកំពង់ស្ពឺ?** ៤

១. ទីតាំងដ៏ល្អ
២. កម្លាំងពលកម្មឧស្សាហកម្មប្រកបដោយបទពិសោធន៍
៣. វិស័យសេវាកម្មហិរញ្ញវត្ថុដ៏ប្រសើរ
៤. ជីវភាពរស់នៅ
៥. អចលនទ្រព្យដ៏មានតំលៃលើសលុប
៦. ការផ្គត់ផ្គង់ថាមពលអគ្គិសនី

**ឧស្សាហកម្មសំខាន់ៗរបស់ខេត្ត** ៥

កសិកម្ម
ឧស្សាហកម្ម
ទេសចរណ៍

**ការអភិវឌ្ឍន៍ដែលកំពុងដំណើរការ** ៧

**ត្រូវការស្វែងយល់បន្ថែមទៀតទេ?** ៨

**ស្ថិតិ** ៩



របាយការណ៍វិនិយោគនេះផលិតដោយ EMC សំរាប់គំរោងអភិវឌ្ឍន៍សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម នៅកម្ពុជា ដែលអនុវត្តគំរោងដោយអង្គការ DAI ឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ ។








# មតិស្វាគមន៍ពីឯកឧត្តមអភិបាលខេត្ត

កំពង់ស្ពឺគឺជាខេត្តមួយដែលល្បីខាងស្ករត្នោត និងស្រាទឹកត្នោត ។ ប៉ុន្តែក្រៅពីវិស័យកសិកម្ម ខេត្តរបស់យើងមានវិស័យផ្សេងៗជាច្រើនថែមទៀត ។ សព្វថ្ងៃនេះខេត្តរបស់យើងលូតលាស់យ៉ាងខ្លាំង ខាងផ្នែកឧស្សាហកម្មផលិតកម្មធុនស្រាល និងផ្នែកអភិវឌ្ឍន៍តំបន់ទេសចរណ៍មួយចំនួនក្នុងតំបន់ដែលរកចំណូលបានយ៉ាងច្រើនទៀតផង គឺរាប់តាំងពីរាជធានីឧដុង្គដែលជារាជធានីចាស់របស់ខ្មែររហូតដល់រមណីយដ្ឋានគីរីរម្យ ។

ខេត្តកំពង់ស្ពឺមានទីតាំងនៅចន្លោះរាជធានីភ្នំពេញ និងកំពង់ផែសំខាន់នៃក្រុងព្រះសីហនុរបស់ប្រទេសកម្ពុជា ។ ដោយស្ថិតចន្លោះក្រុងព្រះសីហនុ និងរាជធានីភ្នំពេញ និងមានផ្លូវជាតិលេខ៤ឆ្លងកាត់ផងនោះ ខេត្តរបស់យើងជាតំបន់ដ៏សំខាន់មួយសំរាប់ធ្វើអាជីវកម្ម ។

យើងមានពលករវ័យក្មេងពេញកំលាំងពលកម្ម និងឧស្សាហ៍ព្យាយាម ។ ជាលទ្ធផលខេត្តរបស់យើងមានការបង្កើតពាណិជ្ជកម្ម ឧស្សាហកម្មផលិតកម្មធុនស្រាលយ៉ាងច្រើនសម្បើម ។

ដើម្បីបន្តលើកកំពស់មូលដ្ឋានសេដ្ឋកិច្ចរបស់យើង និងបន្តពង្រឹងកិត្តិស័ព្ទរបស់ខេត្តយើងជាតំបន់ប្រកបដោយអំណោយផលសំរាប់ការវិនិយោគ រដ្ឋាភិបាលខេត្តកំពង់ស្ពឺបានខិតខំប្រឹងប្រែងធ្វើការដោយមិនខ្លាចនឿយហត់ដើម្បីពង្រឹងបរិយាកាសអាជីវកម្មនៅក្នុងខេត្ត ។

ទោះជាយ៉ាងណាក៏ដោយក៏យើងមិនបញ្ឈប់ត្រឹមនេះដែរ ។ យើងនៅតែបន្តកែលំអខេត្តរបស់យើងឱ្យកាន់តែមានការទាក់ទាញវិនិយោគទុនបន្ថែមទៀត ព្រមទាំងថែរក្សាសហគ្រាសអាជីវកម្មដែលមានស្រាប់ឱ្យបានគង់វង្សទៀតផង ។

យើងរីករាយចំពោះសក្តានុពលភាពក្នុងការពង្រីង និងពង្រីកមូលដ្ឋានឧស្សាហកម្មរបស់យើងព្រមទាំងបើកចំហទទួលស្វាគមន៍វិនិយោគិនទាំងក្នុង និងក្រៅប្រទេសថែមទៀត ។ យើងនឹងព្យាយាមឱ្យអស់ពីលទ្ធភាពដើម្បីបង្កលក្ខណៈងាយស្រួល និងធ្វើឱ្យវិនិយោគិនចំណាយធនធានតិច ក្នុងការបង្កើត និងការប្រកបមុខជំនួញរបស់ខ្លួន ហើយយើងនឹងប្រឹងប្រែងបំពេញភារកិច្ចរបស់ខ្លួន ដើម្បីធ្វើឱ្យបរិយាកាសអាជីវកម្មប្រកបដោយស្ថេរភាព និង អាចទុកចិត្តបាន ។

ខ្ញុំសូមថ្លែងអំណរគុណដល់ ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិដែលបានជួយឧបត្ថមក្នុងការរៀបចំបង្កើតរបាយការណ៍ វិនិយោគនិងបានបន្តគាំទ្រលើការផ្សព្វផ្សាយការអភិវឌ្ឍន៍វិស័យឯកជននៅក្នុងខេត្តរបស់យើងខ្ញុំ ។

ខ្ញុំទន្ទឹងរង់ចាំធ្វើការជាមួយវិនិយោគិនទាំងអស់ ដើម្បីជួយធ្វើឱ្យអាជីវកម្មរបស់ពួកគេព្រមទាំងខេត្តដែលមានសក្តានុពលរបស់យើងនេះកាន់តែមានភាពរីកចំរើនឡើងថែមទៀត ។ ជាមួយគ្នានេះ ដែរខ្ញុំសូមថ្លែងអំណរគុណដល់ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិដែលបានជួយឧបត្ថម្ភ ក្នុងការរៀបចំបង្កើតរបាយការណ៍វិនិយោគ និងបានបន្តគាំទ្រលើការផ្សព្វផ្សាយការអភិវឌ្ឍន៍វិស័យឯកជននៅក្នុងខេត្តរបស់យើង ។

សូមទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។



**ឯកឧត្តម កង ហ៊ាង**
អភិបាលខេត្តកំពង់ស្ពឺ





# ចំណុចខ្លាំងរបស់ប្រទេស

ជាងមួយទសវត្សរ៍ចុងក្រោយនេះ ប្រទេសកម្ពុជាបានចេញមុខជាអ្នកប្រកួតប្រជែងក្នុងតំបន់ដ៏រឹងមាំ និងរហ័សរហួនដោយមានភោគទ្រព្យ យ៉ាងសម្បូរបែបដែលមានសារៈសំខាន់បំផុតសំរាប់កំណើន និងការអភិវឌ្ឍន៍អាជីវកម្ម ប្រកបដោយជោគជ័យ ។

## បើកទូលាយសំរាប់អាជីវកម្ម

- ពន្ធលើប្រាក់ចំណេញដែលមានតម្លៃទាប – ពន្ធ 20% លើប្រាក់ចំណេញ (ការខាតបង់ ៥ ឆ្នាំទៅមុខ)
- ពុំមានការកំណត់លក្ខខណ្ឌកាន់កាប់បរទេសទេ ។ ប្រទេសកម្ពុជា អនុញ្ញាតឱ្យមានសម្ព័ន្ធអាជីវកម្មរួមគ្នាឬក្រុមហ៊ុនដែលកាន់កាប់ ដោយបរទេសប្រត្តិបត្តិការ 100% ដោយមានសិទ្ធិពេញលេញដែលអាចនាំចូល និងនាំចេញផលិតផលបានស្ទើរគ្រប់ប្រភេទ ។
- វិនិយោគិនទាំងអស់ទទួលបានការការពារប្រកបដោយសមភាព ។
- ប្រទេសកម្ពុជាមានសេរីភាពខាងសេដ្ឋកិច្ចជាង ប្រទេសចិន ឥណ្ឌា វៀតណាម និងឥណ្ឌូនេស៊ី[1] ។
- ពុំមានការគ្រប់គ្រងតម្លៃផលិតផល ឬសេវាណាមួយទេ ។
- ពុំមានការគ្រប់គ្រងការប្តូររូបិយប័ណ្ណបរទេស ឬការកំណត់លក្ខខណ្ឌទៅលើការប្តូររូបិយប័ណ្ណនេះទេ ។
- ពុំមានការកំណត់លក្ខខណ្ឌស្តីពីការបង្វិលទុនទេ ។
- ជាសមាជិកភាពអង្គការពាណិជ្ជកម្មពិភពលោក និង អាស៊ាន ។
- ពុំមានការកំណត់លក្ខខណ្ឌពាណិជ្ជកម្មបរិមាណ និងមានការទំលាក់ថ្លៃរបាំងពន្ធគយទេ ។ ប្រទេសកម្ពុជាអាចទទួលបានការលើកលែងពន្ធ និងការកំណត់កូតានៅលើទីផ្សារពិភពលោកធំៗ (ដូចជាសហរដ្ឋអាមេរិក សហភាពអឺរ៉ុប ជប៉ុន និងបណ្តាប្រទេសសមាជិកអាស៊ានជាច្រើនទៀត) ។
- អាជ្ញាធរខេត្តមានសិទ្ធិអនុម័តការវិនិយោគទុនក្រោម ២ លាន ដុល្លារ ដើម្បីការចាប់ផ្តើមអភិវឌ្ឍន៍អាជីវកម្មឆាប់រហ័ស ។

*"ប្រទេសកម្ពុជា បើកទូលាយយ៉ាងពេញលេញសំរាប់អាជីវកម្ម ហើយរាជរដ្ឋាភិបាលកម្ពុជានឹងព្យាយាមឱ្យអស់ពីសមត្ថភាព ដើម្បីធានានូវបរិយាកាសគួរជាទីពេញចិត្ត និងជោគជ័យ ដល់គ្រប់សហគ្រាសទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។"*

– សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន – នាយករដ្ឋមន្ត្រីនៃ ព្រះរាជាណាចក្រកម្ពុជា ។

## កំលាំងពលកម្មដែលមានតម្លៃទាប

បើប្រៀបធៀបទៅនឹងដៃគូប្រកួតប្រជែងក្នុងតំបន់ជាច្រើន ប្រទេសកម្ពុជារីករាយនឹងទទួលយកអត្រាប្រាក់ឈ្នួលទាបសមរម្យ ក្នុងគោលដៅទាក់ទាញឧស្សាហកម្ម ដែលប្រើកំលាំងពលកម្មច្រើន ។

ឆ្លងកាត់ជាច្រើនឆ្នាំចុងក្រោយនេះ កំលាំងពលកម្មនៅប្រទេសកម្ពុជាបានកើនឡើងជាង 50% ច្រើនជាងពីរដងនៃអត្រានៅក្នុងប្រទេស សមាជិកអាស៊ានផ្សេងទៀត ។ ហើយដោយសារមានប្រជាជនវ័យក្មេងចំនួនច្រើន (ចំនួនពាក់កណ្តាលមានអាយុក្រោម ២០ឆ្នាំ) ទើបធ្វើឱ្យកំណើននៃកំលាំងពលកម្មនេះ នឹងបន្តកើនឡើង ។

## ប្រាក់ឈ្នួលក្នុងឧស្សាហកម្មកាត់ដេរ[2]

| ប្រទេស | អត្រាប្រាក់ឈ្នួលក្នុងមួយម៉ោង (US$) |
|---|---|
| កម្ពុជា | 0.33 |
| ចិន | 0.88[a]/0.66[b] |
| ប៉ាគីស្ថាន | 0.41 |
| ឥណ្ឌា | 0.38 |
| ឥណ្ឌូនេស៊ី | 0.30 |
| បង់ក្លាដេស | 0.39 |

ការចំណាយទៅលើការអប់រំនៅបឋមសិក្សា ដែលជាចំណែកផលិតផល សរុបក្នុងស្រុកមានការកើនឡើងគួរឱ្យកត់សំគាល់នៅកម្ពុជា ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះហើយ បច្ចុប្បន្ននេះកំពុងតែស្មើគ្នាជាមួយនឹងថៃ ។ រដ្ឋាភិបាលមានផែនការបន្តបង្កើនការចំណាយទៅលើផ្នែកអប់រំបន្ថែមទៀត ។

## ទីតាំងយុទ្ធសាស្ត្រក្នុងតំបន់

ប្រទេសកម្ពុជាមានទីតាំងស្ថិតនៅចំកណ្តាលតំបន់ ដែលមានសក្តានុពលបំផុតនៅលើពិភពលោក ។ នៅកណ្តាលប្រទេសថៃ និងប្រទេសវៀតណាម ប្រទេសកម្ពុជាគឺ ជាផ្នែកមួយនៃច្រកសេដ្ឋកិច្ចខាងត្បូងនៃ មហាអនុតំបន់ទន្លេមេគង្គ ដែលលាតសន្ធឹងចេញពីទីក្រុងហូជីមិញរហូត ដល់ទីក្រុងបាងកក ។

ដោយសារទីតាំងយុទ្ធសាស្ត្ររបស់ខ្លួន ប្រទេសកម្ពុជាបានរីករាយនឹង ទទួលយកការគាំទ្រពីសំណាក់អន្តរជាតិដ៏សំខាន់ៗ ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនរបស់ខ្លួនដើម្បីសម្រួលដល់ពាណិជ្ជកម្មក្នុងប្រទេស និងជាមួយប្រទេសជិតខាង ។ ជាលទ្ធផលពាណិជ្ជកម្មជាមួយនឹង ប្រទេសវៀតណាម និងប្រទេសថៃកំពុងតែរីកចម្រើនឡើងយ៉ាងឆាប់រហ័ស ។

1. The Heritage Foundation *លិបិក្រមនៃសេរីភាពសេដ្ឋកិច្ច ឆ្នាំ២០០៨ ។*
http://www.heritage.org/index/

2. *ចំណាំ: a) តំបន់ឆ្នេរ b) តំបន់ដីគោក*
*ប្រភព: បាហ្គាវី (Bargawi) "ឧស្សាហកម្មកាត់ដេរកម្ពុជា – ប្រភព និងការរំពឹងទុកពេលអនាគត" វិទ្យាស្ថានអភិវឌ្ឍការគ្រប់គ្រង ឆ្នាំ ២០០៥ ។*








*" អ្នកមានទីក្រុងធំជាងគេចំនួនពីរនៅក្នុងអាស៊ីនៅអមអ្នក ។ អ្នកមានប្រជាជន ១៥លាននាក់នៅទីក្រុងបាងកក និង ៨លាននាក់ នៅទីក្រុងហូជីមិញ ហើយកំណើនផ្សេងៗមានការកើនឡើងជាលំដាប់នៅភាគកណ្តាលនៃទីក្រុងទាំងពីរ ។ "*

- Edward Hopkins, CB Richard Ellis Group Inc.

# ហេតុអ្វីជ្រើសរើសយកខេត្តកំពង់ស្ពឺ?

## ១. ទីតាំងដ៏ល្អ

ខេត្តកំពង់ស្ពឺស្ថិតនៅចំផ្លូវគមនាគមន៍ដ៏សំខាន់ ដែលនៅចន្លោះទីក្រុងភ្នំពេញជារាជធានីនៃប្រទេសកម្ពុជា និងក្រុងព្រះសីហនុ ជាកំពង់ផែសមុទ្រតែមួយគត់នៃប្រទេសកម្ពុជា ។ ដោយសារមានផ្លូវជាតិដ៏រឹងមាំភ្ជាប់ទីក្រុងសំខាន់ទាំងពីរនេះហើយ ទើបខេត្តកំពង់ស្ពឺជាទីកន្លែងដ៏ល្អបំផុតសំរាប់ជាច្រកក្នុងការនាំចូល និងនាំចេញផលិតផល ព្រមទាំងជាទីផ្សារក្នុងស្រុកផងដែរ ។

**កម្ពុជា_ខេត្តកំពង់ស្ពឺ រយៈពេលធ្វើដំណើរតាមរថយន្តទៅកាន់ទីរូមខេត្តឬក្រុងនានា**




សញ្ញាព្រួញតំណាងឱ្យរយៈពេលនៃការធ្វើដំណើរដោយរថយន្តគិតជាម៉ោងរយៈពេលធ្វើដំណើរទៅកាន់ទីក្រុង បាងកក និង ហូជីមិញ មិនរាប់បញ្ចូលរយៈពេលឆ្លងកាត់ព្រំដែនទេ

ទីរូមខេត្តកំពង់ស្ពឺធ្វើដំណើរត្រឹមតែរយៈពេលមួយម៉ោងប៉ុណ្ណោះ ពីទីក្រុងភ្នំពេញ ធ្វើដំណើររយៈពេល ៣ ម៉ោងពីក្រុងព្រះសីហនុ ហើយធ្វើដំណើរត្រឹមតែ៥ម៉ោងកន្លះប៉ុណ្ណោះពីទីក្រុងហូជីមិញ ។ ពីទីរូមខេត្តកំពង់ស្ពឺ ទៅព្រលានយន្តហោះភ្នំពេញ យើងធ្វើដំណើរត្រឹមតែ ៤០-៤៥ នាទី ប៉ុណ្ណោះ ។

ខេត្តមានហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ដ៏ល្អ ។ ខេត្តកំពង់ស្ពឺមានផ្លូវជាតិដ៏រឹងមាំចំនួន ៥បន្ថែមពីលើផ្លូវជាតិលេខ ៤ ដ៏សំខាន់ដែលលាតសន្ធឹងកាត់ខេត្តនេះទាំងមូល ។ ផ្លូវជាតិលេខ ៥... និង ផ្លូវជាតិលេខ ៥១ តភ្ជាប់ពីខេត្តកំពង់ស្ពឺទៅប្រទេសវៀតណាម និងប្រទេសថៃ ។ ស្ពានពីរខ្សែដែលត្រូវបានកំពុងសាងសង់កាត់ទន្លេមេគង្គ នឹងជួយសម្រួលដល់ពេលវេលាធ្វើដំណើរទៅខេត្តកំពង់ចាម (ដោយឆ្លងកាត់ទីក្រុងភ្នំពេញ) និង ប្រទេសវៀតណាម ។ អាស្រ័យហេតុនេះហើយ ខេត្តកំពង់ស្ពឺ ផ្តល់ភាពងាយស្រួលដល់ការធ្វើដំណើរទៅភ្នំពេញ ក្រុងព្រះសីហនុ ប្រទេសថៃ និងប្រទេសវៀតណាម ។

## ២. កម្លាំងពលកម្មឧស្សាហកម្មប្រកបដោយបទពិសោធន៍

ខេត្តកំពង់ស្ពឺជាកន្លែងសំរាប់មូលដ្ឋានឧស្សាហកម្ម និងផលិតកម្មដ៏ចំបង ។ ដូច្នេះហើយ ប្រជាពលរដ្ឋយើង មានបទពិសោធន៍ធ្វើការងារក្នុងវិស័យទាំងនេះ ។ កម្លាំងពលកម្មការងារនៅខេត្តកំពង់ស្ពឺភាគច្រើន ធ្លាប់បានឆ្លងកាត់ការងារផ្នែកកសិកម្មទោះបីយ៉ាងណាក៏ដោយ កម្លាំងពលកម្ម 18% នៃកម្លាំងពលកម្មសំរាប់ខេត្តកំពង់ស្ពឺ ធ្លាប់បានឆ្លងកាត់ការងារផ្នែកឧស្សាហកម្ម ដែលជាតួលេខខ្ពស់បំផុតសំរាប់ប្រទេសកម្ពុជា បន្ទាប់ពីខេត្តកណ្តាល ។

ជាងនេះទៅទៀត កម្លាំងពលកម្មរបស់យើងខ្ញុំសុទ្ធតែនៅក្មេង (ពាក់កណ្តាលក្នុងចំណោមពួកគេទាំងនោះមានអាយុក្រោម២០ឆ្នាំ) ដូច្នេះហើយ កម្លាំងពលកម្មទាំងនោះនឹងបន្តរីកលូតលាស់បន្ថែមទៀត ។

ការចំណាយលើការសិក្សានៅបឋមសិក្សា ជាផ្នែកមួយនៃផលិតផលក្នុងស្រុកសរុបបានកើតឡើងគួរឱ្យកត់សំគាល់ក្នុងប្រទេសកម្ពុជា នៅកំឡុងឆ្នាំថ្មីៗនេះ ហើយពេលនេះការចំណាយគឺប្រហែលគ្នានឹងប្រទេសថៃដែរ ។ ហើយខេត្តកំពង់ស្ពឺក៏មិនខុសប្លែកអ្វីនោះដែរ ។ រដ្ឋាភិបាលក៏គ្រោងបន្តបង្កើនការចំណាយលើវិស័យអប់រំផងដែរ ។

### ប្រជាសាស្ត្រអនុគ្រោះ[3]




*3. វិទ្យាស្ថានជាតិស្ថិតិ ជំរឿនចំនួនប្រជាជននៅក្នុងប្រទេសកម្ពុជា ឆ្នាំ ២០០៤ ។*





## ៣. វិស័យសេវាកម្មហិរញ្ញវត្ថុដ៏ប្រសើរ

ដោយសារវិស័យពាណិជ្ជកម្មមានការលូតលាស់ និងដោយសារប្រជាជនថ្នាក់កណ្ដាលមានការកើនឡើង វិស័យហិរញ្ញវត្ថុនៅក្នុងខេត្តក៏រីកដុះដាលយ៉ាងល្អផងដែរ។ មានសាខាធនាគារចំនួន ១០ កន្លែងស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ។

យើងថែមទាំងមានការិយាល័យមីក្រូហិរញ្ញវត្ថុចំនួន ១៥កន្លែង ដោយមានអ្នកមកខ្ចីប្រាក់ចំនួនជាង ៦០,០០០ នាក់ ត្រូវជា ៧% នៃប្រជាជនក្នុងស្រុក។ តួលេខនេះមានចំនួនច្រើនជាងតួលេខជាមធ្យមទូទាំងប្រទេស ។

ពាណិជ្ជកម្មរបស់យើងបានផ្ដល់ដើមទុនដែលគេត្រូវការដើម្បីធ្វើវិនិយោគទុនប្រកបដោយផ្លែផ្កា ទោះជាសហគ្រាសខ្នាតតូចត្រូវបានដាក់ឱ្យដំណើរការដើម្បីបំរើសេចក្ដីត្រូវការអង្គការ ឬអង្គភាពធំៗដែលត្រូវការដើមទុនវិនិយោគចាំបាច់យ៉ាងណាក្ដី ។

## ៤. ជីវភាពរស់នៅ

ខេត្តកំពង់ស្ពឺតែងទាក់ទាញអ្នកជំនួញ ដែលប្រាថ្នាចង់បានភាពថ្កុំថ្កើនផ្នែកសេដ្ឋកិច្ច និងកិរិតជីវភាពរស់នៅសមរម្យ ។ ខេត្តយើងខ្ញុំ បានទាក់ទាញចំណាប់អារម្មណ៍ទេសចរណ៍ក្នុងស្រុកចំរុះ មានផ្លូវងាយស្រួលទៅកាន់ទីផ្សារ ព្រមទាំងរមណីយដ្ឋានជាតិនានា និងអាចធ្វើដំណើរយ៉ាងឆាប់បំផុតចូលទៅកាន់រាជធានី ឬសហគមន៍ឆ្នេរសមុទ្រក្រុងព្រះសីហនុដ៏ល្បីល្បាញ ។ កំពង់ស្ពឺជាខេត្តជម្រើសសំរាប់អ្នកធ្វើអាជីវកម្មដ៏ជោគជ័យ ដែលដើរស្វែងរកអស់ពេលជាយូរណាស់មកហើយ ។

## ៥. អចលនទ្រព្យដ៏មានដំលៃលើសលុប

ខេត្តកំពង់ស្ពឺជាខេត្តធំមួយ ដែលមានផ្ទៃដីធំទូលាយសំរាប់ផលិតកសិកម្ម និងកសិឧស្សាហកម្ម។

ដើម្បីប្រើប្រាស់ផ្ទៃដីសំរាប់ការអភិវឌ្ឍន៍ប្រកបដោយចេរភាព និងទទួលជោគជ័យនោះ យើងត្រូវតែជ្រោមជ្រែង និងចូលរួមធ្វើការយ៉ាងសកម្ម ជាមួយក្រុមហ៊ុននានា ដើម្បីផ្ដល់ដីដ៏សមស្រប សំរាប់ការធ្វើវិនិយោគទុនរបស់គេ ។ ជាពិសេស ផ្ទៃដីដែលអាចប្រើប្រាស់បានសំរាប់ការធ្វើកសិឧស្សាហកម្ម ។

ដើម្បីពង្រីកបន្ថែមនូវគុណភាពដី យើងបានធ្វើការងារយ៉ាងសកម្ម ដើម្បីកែលំអប្រព័ន្ធធារាសាស្ត្រក្នុងខេត្ត ។ ប្រទេសកូរ៉េខាងត្បូងកំពុងស្ថាបនាអាងស្តុកទឹកមួយកន្លែង ហើយប្រទេសឥណ្ឌា និងប្រទេសប៉ាគីស្ថានបានធ្វើការសិក្សាសំរាប់ការសាងសង់បន្ថែម។ អាងស្តុកទឹក ៣ កន្លែងកំពុងត្រូវបានសាងសង់នៅតំបន់ភ្នំក្នុងខេត្ត ដើម្បីស្ដុកទឹកសំរាប់ផ្គត់ផ្គង់នៅរដូវប្រាំង ។

## ៦. ការផ្គត់ផ្គង់អគ្គិសនី

ខេត្តកំពង់ស្ពឺទទួលថាមពលអគ្គិសនីពីប្រភពបី រួមទាំងកន្លែងផលិតថាមពលស្វ័យយ័តក្នុងស្រុកចំនួន ២១កន្លែងផ្សេងទៀត ។

ជាពិសេស រោងចក្រវារីអគ្គិសនី ៣ កន្លែងនៅគីរីរម្យ ជាប្រភពថាមពលដ៏សំខាន់សំរាប់ខេត្តកំពង់ស្ពឺ។ ទីកន្លែងវារីអគ្គិសនីចំនួនបីកន្លែងផ្សេងទៀតត្រូវបានរកឃើញនៅក្នុងខេត្ត (មានកំលាំងប្រហែល ២០មេហ្គាវ៉ាត់ នៅកន្លែងនីមួយៗ) ដែលជាប្រភពថាមពលផ្គត់ផ្គង់នាពេលអនាគត សំរាប់មូលដ្ឋានសេដ្ឋកិច្ចកំពុងរីកលូតលាស់របស់យើង ។ រោងចក្រថ្មីចំនួនពីរ ត្រូវបានគេរំពឹងថា នឹងត្រូវសាងសង់នៅឆ្នាំ ២០០៩ ដល់ ឆ្នាំ ២០១៣ ។ មានរោងចក្រជាច្រើនបាននាំចូលអគ្គិសនីពី ប្រទេសវៀតណាមកាត់តាមខេត្តតាកែវ ។

ម្យ៉ាងវិញទៀត គំរោងផ្ទេរថាមពល និងអគ្គិសនីយកម្មជនបទ ដែលឧបត្ថម្ភដោយប្រាក់កំចីពីធនាគារពិភពលោក ៤០លានដុល្លារ នឹងលើកកំពស់បណ្ដាញថាមពលពីទីក្រុងភ្នំពេញមកកាន់ខេត្តកំពង់ស្ពឺ - យើងប្ដូរផ្ដាច់ក្នុងការធានាថា អាជីវកម្មក្នុងខេត្តរបស់យើងមាននូវថាមពលគ្រប់គ្រាន់ដែលត្រូវការដើម្បីប្រតិបត្តិការដោយប្រសិទ្ធិភាព និងអស់ថវិកាតិច។

អគ្គិសនីដែលបានផ្គត់ផ្គង់ដោយអគ្គិសនីជាតិកម្ពុជា នៅក្នុងខេត្តកំពង់ស្ពឺ មានតម្លៃ ៧២០ រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោង ។ រោងចក្រដែលប្រើប្រាស់អគ្គិសនីឯកជន ត្រូវបង់ថ្លៃប្រហែល ១០០០ រៀលទៅ ១៥០០ រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង ។ ខេត្តមានគម្រោងផ្គត់ផ្គង់អគ្គិសនីពីប្រភពថ្មីនៅក្នុងតម្លៃ ៥០០ រៀលទៅ ៦០០ រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោង ។

# ឧស្សាហកម្មសំខាន់ៗរបស់ខេត្ត

ជោគជ័យរបស់យើងក្នុងកិច្ចការគាំទ្រវិស័យពាណិជ្ជកម្មដ៏ស្រួចស្រាវ បានធ្វើឱ្យខេត្តកំពង់ស្ពឺក្លាយជាគោលដៅឈានមុខគេសំរាប់សហគ្រាសនានាក្នុងប្រទេសកម្ពុជា ។

## កសិកម្ម

ដំណាំដំឡូងមីនៅខេត្តកំពង់ស្ពឺ បានកើនឡើងជានិរន្តរ៍នៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ។ ដំណាំនេះគេរំពឹងថា នឹងបន្តកើនឡើងតទៅទៀត ដោយមានរោងចក្រជីវៈអេតាណុលបើកនៅក្នុងខេត្តកណ្ដាល ដែលនឹងនាំយកប្រភពដំឡូងមីមកពីខេត្តកំពង់ស្ពឺ ។ ក្រុមហ៊ុន MH Bio-Energy Group បញ្ជាក់ថា គេបានដាំដំឡូងមីនៅលើទំហំដី ៨ ០០០ ហិកតា នៅក្នុងខេត្តកំពង់ស្ពឺ ដែលត្រូវការជួលមនុស្សធ្វើការចំនួន ១០ ០០០ នាក់ ។

ខេត្តកំពង់ស្ពឺមានចំការត្នោតដ៏ធំជាងគេក្នុងប្រទេសកម្ពុជា។ ស្ករត្នោត និងស្រាទឹកត្នោតជាផលិតផលដ៏សំខាន់ និងមានសក្ដានុភាពសំរាប់ការផលិតផ្សេងៗទៀត ។ ក្រុមហ៊ុនផលិតស្រាទឹកត្នោតធំបំផុតរបស់ប្រទេសកម្ពុជា ខុនហ្វ្រែល (Confirel) ជាប្រភពផ្គត់ផ្គង់ទឹកត្នោតផ្អែម នៅខេត្តកំពង់ស្ពឺ ។ ខុនហ្វ្រែល (Confirel) សង្ឃឹមថានឹងបាននាំចេញស្ករត្នោត ៣០ តោន នៅឆ្នាំ ២០០៨ ដែលលើសពី ២០ តោននៅក្នុងឆ្នាំ ២០០៧ ។

ដើមត្នោតអាចផលិតចេញទៅជាផលិតផលដ៏ទៃទៀត ដូចជាសំភារៈសិប្បកម្មនានា។ អាជ្ញាធរខេត្ត មានចំណាប់អារម្មណ៍ក្នុងការស្វែងរកវិធីប្រើប្រាស់ថ្មៃប្រឌិតថ្មីៗសំរាប់ភោគទ្រព្យដើមត្នោតរបស់ខ្លួន ។ ខេត្តនៅបានដាំដំណាំរួមផ្សំដូចជា ស្វាយ ឪឡឹក និងដំណាំបន្លែផ្សេងទៀតជាច្រើន ។

ខេត្តកំពង់ស្ពឺមានឧស្សាហកម្មវារីវប្បកម្មមួយដែលសកម្ម ។ ក្រុមហ៊ុន Ocean King បានដំណើរការកន្លែងចិញ្ចឹមត្រី លើដីទំហំ ២០ ហិកតា នៅក្នុងខេត្តកំពង់ស្ពឺ ។ ក្រុមហ៊ុននេះក៏បានផ្គត់ផ្គង់កូនត្រីដល់អ្នកចិញ្ចឹម នៅក្នុងមូលដ្ឋានផ្សេងទៀតផងដែរ ។ ក្រុមហ៊ុនបាននិយាយថា ក្រុមហ៊ុនមានគម្រោងសាងសង់រោងចក្រកែច្នៃសាច់ត្រីមួយកន្លែង នៅក្នុងទីក្រុងភ្នំពេញ ហើយនឹងនាំចេញសាច់ត្រី ១ ០០០ តោន ។

ខេត្តជាទីកន្លែងតាំងនៅនៃសហគ្រាសកសិកម្មនានា ដូចជាសហគ្រាសទាំងឡាយដែលបានធ្វើការដាំដុះដំឡូង ព្រមទាំងស្វាយចន្ទីជាដើម ។





## ការធ្វើវិនិយោគទុនវិស័យកសិកម្មដែលបានអនុញ្ញាតក្នុងខេត្តកំពង់ស្ពឺ

| ឈ្មោះ | សកម្មភាព | ចំនួននិយោជិត |
|---|---|---|
| ក្រុមហ៊ុនវិនិយោគទុនកសិកម្មតារាស៊ី | កសិកម្ម | 150 |
| ក្រុមហ៊ុន MH Bio-Energy Group | ដំឡូងមី | 10 000 |
| You He Fa | កសិផលិតផល | 145 |
| ក្រុមហ៊ុនអភិវឌ្ឍន៍ហ្គ្រីនខល័រ អេច អែម ធី | កសិផលិតផល | 93 |
| ក្រុមហ៊ុនខេមរិន្ទ | កសិផលិតផល | 83 |
| ក្រុមហ៊ុនកសិអភិវឌ្ឍន៍គីរីរម្យ | កសិផលិតផល | 135 |
| ក្រុមហ៊ុន Ocean King (កម្ពុជា) | ត្រី និងបង្គា | 314 |

បន្ថែមលើការវិនិយោគទុនដែលបានអនុញ្ញាតទាំងនេះ មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលថ្នាក់ខេត្តបានបញ្ជាក់ថា ឧស្សាហករផលិតស្ករត្រូវបានលើកទឹកចិត្តឱ្យធ្វើការដាំដុះដំណាំអំពៅលើដីសម្បទានរបស់ខេត្តចំនួន ១០.០០០ ហិកតា ។

## ឧស្សាហកម្ម

ខេត្តកំពង់ស្ពឺមានរោងចក្រកាត់ដេរចំនួនប្រហែល ១០ ក្នុងចំណោមរោងចក្រទាំង ១៦ កន្លែងដែលកំពុងតែសាងសង់បន្ថែម ។ សរុបចំនួនកម្មកររោងចក្រនៅក្នុងខេត្តបច្ចុប្បនេះមានប្រហែល ៣៨ ០០០ នាក់ ។ ខេត្តជឿជាក់ថា នឹងមានសក្តានុពលសម្រាប់កម្មករចំនួន ២០ ០០០ នាក់ទៀត ។

| សកម្មភាព | ចំនួនសហគ្រាស | ចំនួនកម្មករ |
|---|---|---|
| សហគ្រាសដាំដំឡូង ស្វាយចន្ទី.... | 16 | 12,000 |
| សំលៀកបំពាក់ និងស្បែកជើង | 15 | 13,000 |
| ផលិតផលឈើ | 10 | គ្មាន |
| រោងចក្រស៊ីម៉ង់តិ៍ | 1 | 100 |
| កន្លែងយកថ្ម | 19 | គ្មាន |
| សិប្បកម្ម | 3000 | គ្មាន |

បើតាមមន្ត្រីរដ្ឋាភិបាលក្នុងខេត្តបញ្ជាក់ថា កំណើនឧស្សាហកម្មកាត់ដេរក្នុងស្រុកបានផ្តល់នូវ:

១. ហេដ្ឋារចនាសម្ព័ន្ធមានស្រាប់ដែលទ្រទ្រង់ដល់បណ្តុំផ្ចិតរោងចក្រកាត់ដេរថ្មីៗ នៅក្នុងស្រុកសំរោងទង ។

២. ការខិតជិតទៅរកទីផ្សារ ។

៣. ការកកើតផ្លូវជាតិលេខ៤ឆ្លងកាត់ខេត្តដែលបន្ទាប់មកដឹកជញ្ជូនទៅកាន់កំពង់ផែក្រុងព្រះសីហនុសំរាប់ការនាំចេញ ។

## តំបន់ឧស្សាហកម្មនៅក្នុងខេត្តកំពង់ស្ពឺ




អាជីវកម្មតូច ជាច្រើនបានដំណើរការក្នុងខេត្តរបស់យើង ដោយមានអាជីវកម្មជាង ៤០០ បានចុះឈ្មោះនៅមន្ទីរពាណិជ្ជកម្មខេត្ត ។ ជាងនេះទៅទៀត នៅមានសហគ្រាសធុនតូចរាប់ពាន់ផ្សេងទៀត ។ សហគ្រាសទាំងនេះមានសកម្មភាពដូចជា:

- កិនស្រូវ
- ផលិតថាមពល
- ផលិតកម្មចំណីអាហារ និងភេសជ្ជៈ
- ផលិតកម្មសង្ហារឹម
- សិប្បកម្ម
- ជួសជុលម៉ាស៊ីន
- ការលក់រាយ និងលក់ដុំ
- បដិសណ្ឋារកិច្ច
- សេវាកម្មសុខភាព

ឧទាហរណ៍ មានគ្រួសារប្រហែល ១៦០ គ្រួសារ នៅក្នុងស្រុកបសេដ្ឋ ស្ថិតនៅចម្ងាយ ៥៧ គីឡូម៉ែត្រ ខាងត្បូងទីរួមខេត្ត សស្រាក់សស្រាំ ក្នុងការប្រកបរបរត្បាញក្រមា ។

ខេត្តមានកន្លែងយកថ្មប្រមាណជា ២០ កន្លែង (ដែលមានសក្តានុពល សំរាប់ទីកន្លែងជាច្រើនផ្សេងទៀត) ។ ថ្មីៗនេះ ក្រុមហ៊ុនដប់ប្រាំបួន បានប្រតិបត្តិការនៅតាមកន្លែងយកថ្មជាច្រើនកន្លែងនិងក្រុមហ៊ុនចំនួន២៧ ក្រុមហ៊ុនទៀត មានអាជ្ញាប័ណ្ណធ្វើអាជីវកម្មប៉ុន្តែមិនទាន់បានប្រតិបត្តិការនៅឡើយ ។ ខេត្តបានទទួលការដាក់ពាក្យសុំអាជ្ញាប័ណ្ណចំនួន ១៤ ក្រុមហ៊ុនទៀតប៉ុន្តែមិនទាន់មានការអនុញ្ញាតនៅឡើយ ។ មានក្រុមហ៊ុនយកខ្សាច់ ៣៣ ក្រុមហ៊ុនបន្ថែមទៀត ។

ខេត្តសម្បូរដោយថ្មបាយក្រៀម ។ ទាំងនេះ ធ្វើអោយមានការហូរចូលនូវឧស្សាហកម្មសំណង់ក្នុងស្រុក ។ ខេត្តកំពង់ស្ពឺមានរោងចក្រស៊ីម៉ង់តិ៍មួយកន្លែងផងដែរ ។

ខេត្តមានសក្តានុពលភោគទ្រព្យរ៉ែមួយចំនួនរួមមាន សំណ ទង់ដែង ស័ង្កសី នៅសំរោង និងឃ្នងអាយ សំណប៉ាហាំង និងរ៉ែដែក នៅឃ្នងអាយ ប្រាក់នៅសំរោង និងថ្មកំបោរនៅភ្នំចាស់ ។ ថ្មីៗនេះ មានកន្លែងយករ៉ែដែកមួយ និងរ៉ែប្រាក់មួយកន្លែងត្រូវបានគេកំពង់ធ្វើការពិចារណា ។





ខេត្តមានសហគ្រាសផលិតផលឈើហ៊ុបសំរាប់ផលិតគ្រឿងសង្ហារឹម និងសំភារៈដទៃទៀត ។ ស្របពេលដែលយើងប្រឹងប្រែងធ្វើការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព នោះយើងក៏នៅតែធ្វើការងារយ៉ាងសកម្មដើម្បីស្ថាបនាអាជីវកម្មដែលមានលក្ខណៈល្អប្រសើរចំពោះបរិស្ថាន ដែលបានប្រើប្រាស់ធនធានធម្មជាតិសម្បូរបែបរបស់យើង ។

## ទេសចរណ៍

ខេត្តកំពង់ស្ពឺផ្តល់ឱ្យភ្ញៀវទេសចរណ៍នូវធនធានធម្មជាតិដ៏អស្ចារ្យ ព្រមទាំងបទពិសោធន៍ផ្នែកវប្បធម៌ ។ ខេត្តមានរមណីយដ្ឋានជាច្រើន ទឹកពុះ ភ្នំ (រួមទាំងភ្នំដែលខ្ពស់ជាងគេនៅប្រទេសកម្ពុជា) និងទឹកជ្រោះ ។ ឧទ្យានជាតិគីរីរម្យជាកន្លែងរមណីយដ្ឋានធម្មជាតិដ៏ល្បីល្បាញមួយ ។ រមណីយដ្ឋាននេះស្ថិតនៅតាមជួរភ្នំដែលមានចំងាយ ១១៧ គីឡូម៉ែត្រពីក្រុងភ្នំពេញ ហើយសម្បូរទៅដោយ ដើមស្រល់ និងទឹកជ្រោះដ៏ស្រស់ត្រកាល ។

អតីតរាជធានីឧដុង្គនៃរាជាណាចក្រកម្ពុជា ជាទីតាំងប្រវត្តិសាស្ត្រដ៏សំខាន់នៅក្នុងខេត្ត ។ មន្ទីរវប្បធម៌ខេត្តកំពង់ស្ពឺ បានបង្កើតគម្រោងដ៏ធំមួយក្នុងការអភិវឌ្ឍន៍ធម្មជាតិយ៉ាងខ្លាំងក្លា និងតំបន់ទេសចរណ៍វប្បធម៌នៅខេត្តកំពង់ស្ពឺ ។

| ឈ្មោះ | ការបរិយាយ |
|---|---|
| ប្រាសាទក្អែកពង | ទីតាំងប្រវត្តិសាស្ត្រ ។ ប្រាសាទបុរាណដែលមាន ទីតាំងស្ថិតនៅខាងជើងស្រុកភ្នំស្រួច ។ |
| ភ្នំព្រះ | តំបន់ទេសចរណ៍ធម្មជាតិ ។ ភ្នំនេះស្ថិតនៅប៉ែកអាគ្នេយ៍នៃស្រុកថ្ពង ។ |
| ភ្នំចាស់ | តំបន់ធម្មជាតិ ។ ភ្នំនេះស្ថិតនៅខាងលិចស្រុកឱរ៉ាល់ ។ |
| ទេទឹកពុះ | តំបន់ធម្មជាតិ ។ ទឹកពុះមានទីតាំងស្ថិត នៅខាងកើតស្រុកឱរ៉ាល់ ។ |
| ប្រាសាទតាព្រហ្ម | តំបន់ធម្មជាតិ ។ ប្រាសាទបុរាណនេះ មានទីតាំងស្ថិតនៅទិសពាយព្យនៃស្រុកឧដុង្គ ។ |
| ស្រះសារាពៅយុទ្ធ | តំបន់ប្រវត្តិសាស្ត្រ ។ ស្រះនេះមានទីតាំងស្ថិតនៅទិសនិរតីនៃស្រុកឧដុង្គ ។ |
| ស្រះជូនណាត | តំបន់ប្រវត្តិសាស្ត្រ ។ ស្រះនេះមានទីតាំងស្ថិតនៅទិសពាយព្យនៃស្រុកគងពិសី ។ |

## ឱកាសអាជីវកម្ម

ខេត្តរបស់យើងផ្តល់ឱកាសយ៉ាងច្រើនសំរាប់អាជីវកម្មថ្មីៗ ដូចយើងបានឃើញយ៉ាងច្បាស់តាមរយៈប្រភេទក្រុមហ៊ុននានា ដែលកំពុងតែដំណើរការនៅទីនេះស្រាប់ ។ យើងមើលឃើញឱកាសសំខាន់ៗ សំរាប់អាជីវកម្ម ដើម្បីទាញយកប្រយោជន៍ពីកម្លាំងប្រកួតប្រជែងតាមរយៈការធ្វើវិនិយោគទុនបន្ថែម នៅក្នុងផ្នែកៈ

- **សិប្បកម្ម និងផលិតកម្មស្ទូត្រ** ដែលបំរើភ្ញៀវទេសចរណ៍ទៅទស្សនាក្នុងខេត្តក៏ដូចជាបំរើឱ្យទីផ្សារនាំចេញ ។
- **កសិកម្ម** សក្តានុពលចំពោះស្រូវ ផ្លែឈើ និងដំណាំផ្សេងៗទៀត ក៏ដូចជាការចិញ្ចឹមសត្វផងដែរ ជាពិសេសនៅក្នុងស្រុកភ្នំស្រួច ជុំវិញសួនឧទ្យានជាតិគីរីរម្យ ។
- **កសិពាណិជ្ជកម្ម** ជាពិសេស ការកែច្នៃចំណីអាហារ ។ យើងមានឱកាសសំខាន់ក្នុងការបន្ថែមតម្លៃទៅលើទិន្នផលកសិកម្មរបស់យើង ។ ដើមត្នោតជាច្រើនរបស់យើង និងបង្កើនឱកាសក្នុងការផលិតស្ករ និងស្រា ។
- មានឱកាសសំខាន់ៗ ក្នុងការកែច្នៃផលិតផលសាច់សត្វ ដោយសារតែមានចំនួនមានជ្រូក គោក្របីជាច្រើន ។
- **ឧស្សាហកម្មធុនស្រាល** រួមមានដូចជាវិស័យកាត់ដេរ កំលាំងពលកម្មដែលមានតម្លៃទាបជាច្រើន ហេដ្ឋារចនាសម្ព័ន្ធ និង បរិយាកាសអាជីវកម្មអនុគ្រោះជាដើម ។
- **ការយករ៉ែ និងការយកថ្ម** ។ ខេត្តមានសក្តានុពលយ៉ាងខ្ពស់ ចំពោះការយករ៉ែ និងការប្រមូលថ្ម និងខ្សាច់ ដើម្បីការសាងសង់ ឧស្សាហកម្មដែលមានស្រាប់ ។

## ការអភិវឌ្ឍន៍ដែលកំពុងដំណើរការ

ទោះបីជាយើងមានមោទនភាព ចំពោះសមិទ្ធផលនានារបស់យើងក៏ដោយក៏យើងនៅតែពង្រឹង និងកែលំអការទាក់ទាញផ្នែកវិនិយោគ ឱ្យកាន់តែមានភាពប្រសើរថែមទៀត ។ យើងនៅតែសកម្មក្នុងការកសាងរចនាសម្ព័ន្ធអាជីវកម្មរបស់យើង និងក្នុងការទាក់ទាញសហគ្រាសអាជីវកម្មឈានមុខគេ ឱ្យចូលមកខេត្តរបស់យើង ។

គោលនយោបាយសេដ្ឋកិច្ចថ្នាក់ខេត្តប្រចាំខេត្តកំពង់ស្ពឺ ឆ្លុះបញ្ចាំងយ៉ាងច្បាស់នៅគោលនយោបាយរាជរដ្ឋាភិបាលកម្ពុជា ។ គោលគំនិតសំខាន់ទាំងពីរ គឺត្រូវការពង្រឹងវិស័យឯកជនជាប្រព័ន្ធតាមរយៈ (១) ការលើកកំពស់បរិយាកាសអាជីវកម្មឱ្យមានប្រសិទ្ធផល និងប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ (២) ការបង្កើនការបណ្តាក់ទុនបរទេស (FDI) និង (៣) ការគាំទ្រដល់សហគ្រាសធុនតូច និងមធ្យមសំរាប់ប្រទេស ។ បន្ថែមលើកិច្ចគាំទ្រវិស័យទេសចរណ៍ដែលបានរៀបរាប់ខាងដើម អាជ្ញាធរខេត្តកំពង់ស្ពឺនឹងយកចិត្តទុកដាក់លើសកម្មភាពមួយ ចំនួនដូចខាងក្រោមៈ

- កិច្ចប្រឹងប្រែងបន្ត ដើម្បីទាក់ទាញឧស្សហកររោងចក្រកាត់ដេរ មកកាន់ខេត្តក្នុងគោលបំណងទាញយកប្រយោជន៍ពីឧស្សាហកម្ម ដែលមានស្រាប់ដែលបានបង្កើតឡើងដោយក្រុមឧស្សាហកម្មកាត់ដេរ និងទាញប្រយោជន៍ពីច្រកទៅកាន់ទីផ្សារសំខាន់ ឬចំនុចនាំចេញផ្សេងៗ ។
- ការទាក់ទាញការវិនិយោគទុនថ្មីៗ ក្នុងវិស័យកសិកម្ម តាមរយៈធារាសាស្ត្រដែលបានកែលំអ និងការវិនិយោគទុនដើម្បីបង្កើនផលិតកម្ម ។
- បង្កើនការបណ្តុះបណ្តាលជំនាញ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់សំខាន់ៗ

- ជួយជ្រោមជ្រែងដល់អាជីវកម្មនានា ក្នុងការស្វែងរកទីផ្សារនាំចេញសំរាប់ផលិតផលរបស់ពួកគេ ។

ដៃគូអភិវឌ្ឍន៍មួយចំនួនកំពុងជួយជ្រោមជ្រែងក្នុងការអភិវឌ្ឍវិស័យឯកជនប្រចាំខេត្តកំពង់ស្ពឺនៅក្នុងតំបន់សំខាន់ៗមួយចំនួនដូចជា:

| គម្រោង | ដៃគូអភិវឌ្ឍន៍ | វិស័យ |
|---|---|---|
| គំរោងផ្សព្វផ្សាយកសិកម្មកម្ពុជាអូស្ត្រាលីជំហានទី២ (CAAEP II) | AusAID | កសិកម្ម |
| ការសិក្សាលើការអភិវឌ្ឍន៍កសិកម្មទូលំទូលាយនៅស្ទឹងព្រែកត្នោត | JICA | ដំណាំស្រូវ |
| គំរោងផលិតកម្មចិញ្ចឹមសត្វខ្នាតតូច (SLPP) | EC | ចិញ្ចឹមសត្វ |
| គំរោងអភិវឌ្ឍវិស័យកសិកម្ម | ADB | កសិកម្ម |
| គំរោងអភិវឌ្ឍន៍សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និង ខ្នាតមធ្យមនៅកម្ពុជា (CambodiaMSME) | USAID | បសុសត្វ ត្រី ជ្រូក ការកែច្នៃផលិតផលកសិកម្ម ឡូតដូ-គ្រឿង |

## ត្រូវការស្វែងយល់បន្ថែមទៀតទេ?

សំរាប់ព័ត៌មានបន្ថែម ស្តីអំពីឱកាសវិនិយោគ និងការអភិវឌ្ឍន៍នៅក្នុងខេត្តកំពង់ស្ពឺ សូមទាក់ទង:

**លោក វ៉ាន់ សុខា**

អគ្គលេខាធិការសាលាខេត្តកំពង់ស្ពឺ និងជាលេខាធិការនៃគណៈកម្មការវិនិយោគទុនខេត្ត
(855) 012 843 974

**www.cambodiainvestment.gov.kh**
**www.investincambodia.com**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា - គណកម្មការវិនិយោគកម្ពុជា
ទូរស័ព្ទ: (855) 23 981 154
អ៊ីមែល: CDC.CIB@online.com.kh

វិទ្យាស្ថានជាតិស្ថិតិ:
www.nis.gov.kh

### ក្រសួងនានា

ក្រសួងពាណិជ្ជកម្ម:
www.moc.gov.kh

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ:
www.mef.gov.kh

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល:
www.mine.gov.kh

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ:
www.mlv.gov.kh

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់:
www.mlmupc.gov.kh

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍:
www.mptc.gov.kh

ក្រសួងសាធារណការ និងដឹកជញ្ជូន:
www.mpwt.gov.kh

ក្រសួងទេសចរណ៍:
www.mot.gov.kh

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ:
www.maff.gov.kh

### ផ្សេងៗ

សមាគមន៍ឧស្សាហកម្មកាត់ដេរនៅកម្ពុជា:
www.gmac-cambodia.org

សភាពាណិជ្ជកម្មភ្នំពេញ:
www.ppcc.org.kh

សមាគមឧស្សាហកម្មធុនតូច និងមធ្យមភ្នំពេញ
www.smecambodia.org

| ស្ថានភាពទូទៅខេត្តកំពង់ស្ពឺ | |
|---|---|
| ចំនួនប្រជាជន: | 762,500 |
| អាយុពី 15-64: | 56% |
| សមាមាត្រការងារក្នុងវិស័យកសិកម្ម: | 65% |
| លំដាប់ថ្នាក់ភាពក្រីក្ររបស់ខេត្ត: | 23/24 |
| ផ្ទៃដី: | 7,017 km² |
| ដង់ស៊ីតេប្រជាជន: (% ចំនួនប្រជាជនជាមធ្យម) | 137% |
| ចំនួនស្រុក: | 8 |
| ចំនួនឃុំ: | 87 |

| ស្ថានភាពដីក្នុងខេត្តកំពង់ស្ពឺ |
|---|
| ប្រភេទ: ភាគច្រើនជាប្រភេទដីច្រោះ និង ដីជាំទឹកដាំដុះ ។ ហើយជាប្រភេទដីប្រផេះល្បប់ ដីប្រផេះអាស៊ីដ ដីក្នុងតំបន់ជាំទឹកតាមស្រទាប់ និង ដីជាំទឹកពណ៌ប្រផេះ ។ |
| កម្រិតជីវជាតិ: មានភាពខុសគ្នាទូទាំងខេត្ត ចាប់ពីទំនាប ដល់ ខ្ពង់រាប ។ |

| អត្រាពន្ធនៅកម្ពុជា | | |
|---|---|---|
| ពន្ធលើប្រាក់ចំណេញ | ធម្មតា | 20% |
| | អត្រាប្រាក់ លើក-ទឹកចិត្ត | 0% ឬ 9% |
| | | |
| ពន្ធអតិបរមា | | 1% ប្រាក់ចំណូល |
| ពន្ធកាត់ទុក | | 15% |
| ចំណូលបានមកពីការជួលអចលនទ្រព្យ | | 10% |
| ការទូទាត់ចំពោះមនុស្សចំណូលស្រុក | | 14% |
| | | |
| ពន្ធលើប្រាក់ខែ (រៀលក្នុងមួយខែ) | | |
| 0-500,000 | | 0% |
| 500,001-1,250,000 | | 5% |
| 1,250,001-8,500,000 | | 10% |
| 8,500,001-12,500,000 | | 15% |
| 12,500,001 + | | 20% |
| មនុស្សចំណូលស្រុក | អត្រាថេរ | 20% |
| ពន្ធផលប្រយោជន៍បន្ទាប់បន្សំ | | 20% |
| តម្លៃបន្ថែមលើពន្ធ | | 10% |
| | នាំចេញ | 0% |
| ពន្ធផ្ទេរអចលនទ្រព្យ | | 4% |

| ទិន្នន័យម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា | 2005 | 2006 | 2007 | 2008f | 2009f |
|---|---|---|---|---|---|
| កំណើន GDP (%) | 13.5 | 10.8 | 9.6 | 7.5 | 7.0 |
| កំណើននាំចេញ (%) | 12.6 | 19.2 | 8.1 | 5.6 | 8.5 |
| នាំចេញ (% GDP) | 64.2 | 68.0 | 66.7 | 65.7 | 66.1 |
| FDI ($m) | 375 | 475 | 598 | 660 | 759 |
| វិនិយោគទុនបរទេស (% GDP) | 6.0 | 6.5 | 6.9 | 6.7 | 6.8 |

## ចំណាយអាជីវកម្ម

| ដី | លក់ (ក្នុងមួយម៉ែត្រការ៉េ) |
|---|---|
| ភ្នំពេញ | $350-$2,000 |
| ដីសំរាប់អាជីវកម្ម | $30-$200 |
| តំបន់ផ្សេង | $4-$50 |
| ជនបទ | $0.50-$5 |

| ដីសំរាប់ការិយាល័យ | តម្លៃជួលក្នុងមួយខែ |
|---|---|
| សំខាន់ | $9-11/មួយម៉ែត្រការ៉េ |
| បន្ទាប់បន្សំ | $6-8/មួយម៉ែត្រការ៉េ |
| | |
| ប្រាក់ជួលរោងចក្រ | $1.50-$2.50/មួយម៉ែត្រការ៉េក្នុងមួយខែ |
| ប្រាក់ជួលឃ្លាំង | $1.00-$2.50/មួយម៉ែត្រការ៉េក្នុងមួយខែ |

| តម្លៃអគ្គិសនីនៅភ្នំពេញ (excl. SEZs) | | |
|---|---|---|
| ឧស្សាហកម្ម | គីឡូវ៉ាត់ម៉ោង/ខែ | តម្លៃ (រៀល/គីឡូវ៉ាត់) |
| | <45,000 | 600 |
| | 45,000-130,000 | 550 |
| | >130,000 | 500 |
| | កំលាំងវ៉ុលជាមធ្យម | 480 |
| ពាណិជ្ជកម្ម | <45,000 | 650 |
| | 45,000-130,000 | 600 |
| | >130,000 | 500 |
| | កំលាំងវ៉ុលជាមធ្យម | 480 |
| | | |
| ការផ្គត់ផ្គង់ឧស្ម័នឧស្សាហកម្ម | | $0.32/គ.ក្រ |

| តម្លៃពលកម្ម | ប្រាក់ខែ $ ក្នុងមួយខែ |
|---|---|
| អ្នកគ្រប់គ្រងជាន់ខ្ពស់ | 1,000-1,500 |
| អ្នកគ្រប់គ្រងកណ្តាល | 500-1,000 |
| អ្នកគ្រប់គ្រងកម្រិតដំបូង | 240-400 |
| គណនេយ្យករ | 250-400 |
| លេខាធិការ | 120-150 |
| ជំនួយការ | 100-120 |
| អ្នកបើកបរ | 100-120 |
| អ្នកយាមទ្វារ | 50-80 |
| កម្មករ | 50-80 |
| ប្រាក់ឈ្នួលអប្បបរមារបស់កម្មករកាត់ដេរ | 60 |

# ខេត្តកំពង់ស្ពឺ

# សក្តានុពលវិនិយោគ



Photographs by Nathan Horton www.nathanhortonphotography.com

Designed by DESIGNGROUP www.dgcambodia.com